00236764

D99/3/31


# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

## អង្គបុរេជំនុំជម្រះ

PRE-TRIAL CHAMBER
CHAMBRE PRELIMINAIRE


សំណុំរឿងព្រហ្មទណ្ឌលេខ: ០០១/១៨-០៧-២០០៧-អវតក-កសចស (អបជ០២)

**ចំពោះមុខ:** ចៅក្រម ប្រាក់ គីមសាន, ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម ប៉ែន ពេជ្រសាលី
ចៅក្រម Katinka LAHUIS
ចៅក្រម ហួត វុទ្ធី

**កាលបរិច្ឆេទ:** ៥ វិច្ឆិកា ២០០៨

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 05, NOV, 2008
ម៉ោង (Time/Heure): 14:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. Huy

---

## សាធារណៈ:

# សេចក្តីសម្រេចលើសំណើរបស់ក្រុមមេធាវីការពារក្តី សុំចូលអន្តរាគមន៍ជាបន្ទាន់ចំពោះ ទ្រឹស្តីសហកម្មឧក្រិដ្ឋកម្មរួម នៅក្នុងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ "ឌុច"

---

**ការិយាល័យសហព្រះរាជអាជ្ញា**

ជា លាង
Robert PETIT
យ៉េត ចរិយា
William SMITH
ពេជ្រ សម្បត្តិ
Alex BATES

**ជនត្រូវចោទ**

កាំង ហ្កេកអ៊ាវ ហៅ "ឌុច"

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 05, NOV, 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. Huy

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

គង់ ពិសី
ហុង គីមសួន
យុង ផានិត
គឹម ម៉េងឃី
ម៉ុច សុវណ្ណារី
Silke STUDZINSKY
Martine JACQUIN
Philippe CANNONE

**សហមេធាវីការពារក្តី**

ការ សាវុត្ថ
François ROUX

១. **អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") ទទួលបាន "សំណើរួម" របស់ក្រុមមេធាវីការពារក្តី ស្នើសុំចូលអន្តរាគមន៍ជាបន្ទាន់ចំពោះ "ការអនុវត្តន៍ទ្រឹស្តីសហកម្មឧក្រិដ្ឋកម្មរួម" នៅក្នុងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ "ឌុច" ("សំណើ")។ សំណើរួមនេះ ត្រូវបានសហមេធាវីការពារក្តីរបស់លោកស្រី អៀង ធីរិទ្ធ, លោក នួន ជា, និង លោក ខៀវ សំផន ("សហមេធាវីការពារក្តីជនត្រូវចោទ") ដាក់នៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៨។

២. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា នៅថ្ងៃទី២១ ខែសីហា ឆ្នាំ២០០៨ សហព្រះរាជអាជ្ញាបានដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ប្រឆាំងចំពោះដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេត នៅក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ ០០១/១៨-០៧-២០០៧-អវតក/កសចស ("បណ្តឹងឧទ្ធរណ៍")។ នៅក្នុងសារណាបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា ដែលបានដាក់នៅថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០០៨, សហព្រះរាជអាជ្ញាស្នើឱ្យអង្គបុរេជំនុំជម្រះកែប្រែ *លើចំណុចជាច្រើន* ក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ហើយចោទប្រកាន់ជនត្រូវចោទថា បានប្រព្រឹត្តឧក្រិដ្ឋកម្មដូចដែលបានចោទប្រកាន់ តាមរយៈការចូលរួមប្រព្រឹត្តនៅក្នុងសហកម្មឧក្រិដ្ឋកម្មរួម។

៣. សហមេធាវីការពារក្តីរបស់ជនត្រូវចោទអះអាងថា "ខ្លួនមានផលប្រយោជន៍ដោយផ្ទាល់នៅក្នុងបញ្ហាដែលត្រូវផ្តល់សម្អាង ហើយសុំឱ្យអង្គបុរេជំនុំជម្រះធ្វើសេចក្តីសម្រេច"[១]។ សហមេធាវីការពារក្តីស្នើសុំឱ្យអង្គបុរេជំនុំជម្រះអនុញ្ញាតឱ្យខ្លួនផ្តល់អំណះអំណាងលើបញ្ហានៃការអនុវត្តន៍ទ្រឹស្តីសហកម្មឧក្រិដ្ឋកម្មរួម។ សហមេធាវីការពារក្តីសន្និដ្ឋានថា ទោះបីជាខ្លួនមិនមានសិទ្ធិចូលអន្តរាគមន៍ក៏ដោយ សំណើនេះគួរត្រូវទទួលយកដើម្បីជាផលប្រយោជន៍នៃការសន្សំសំចៃសម្រាប់តុលាការ (Judicial Economy) និងដើម្បីទទួលស្គាល់សិទ្ធិរបស់ជនត្រូវចោទទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌។

៤. នៅក្នុងសេចក្តីសន្និដ្ឋានតបដែលបានដាក់នៅថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០០៨ សហព្រះរាជអាជ្ញាបានផ្តល់អំណះអំណាងថា សំណើនេះគឺវាដូចគ្នាបេះបិទទៅនឹងសំណើលើកមុនរបស់សហមេធាវីការពារក្តីរបស់លោក អៀង សារី ហើយសំណើនេះគឺគ្មានខ្លឹមសារអ្វីឡើយ។

៥. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា នៅក្នុង"សេចក្តីសម្រេចលើសំណើរបស់លោក អៀង សារី ដែលស្នើសុំដាក់សេចក្តីសន្និដ្ឋានចំពោះការអនុវត្តន៍ទ្រឹស្តីនៃសហកម្មឧក្រិដ្ឋកម្មរួមនៅក្នុងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ កាំង ហ្កេកអ៊ាវ ហៅ "ឌុច"" ចុះថ្ងៃទី៦ ខែតុលា ឆ្នាំ២០០៨ ("សេចក្តីសម្រេចនៅក្នុងរឿងក្តីរបស់លោក អៀង សារី") ជនត្រូវចោទ អៀង សារី មិនមានសិទ្ធិចូលអន្តរាគមន៍ចំពោះបញ្ហានៃការអនុវត្តន៍ទ្រឹស្តីនៃសហកម្មឧក្រិដ្ឋកម្មរួម នៅក្នុងរឿងក្តីប្រឆាំងនឹងជនត្រូវចោទ ឌុច ឡើយ។ អង្គបុរេជំនុំជម្រះយល់ឃើញទៀតថា សាលដីការបស់ខ្លួននឹង

[១] សំណើរួមរបស់មេធាវីការពារ ស្នើសុំការចូលអន្តរាគមន៍នៅក្នុងការអនុវត្តន៍ទ្រឹស្តី JCE នៅក្នុងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ "ឌុច" ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៨, ឯកសារលេខ D99/3/26 "សំណើ", វាក្យខណ្ឌទី ៥ ។

មិនពាក់ព័ន្ធដោយផ្ទាល់ចំពោះលោក អៀង សារី ឡើយ។ លោក អៀង សារី នៅតែមានលទ្ធភាពផ្តល់អំណះអំណាងចំពោះការអនុវត្តន៍ទ្រឹស្តីនៃសហាកម្មឧក្រិដ្ឋកម្មរួមនៅក្នុងសំណុំរឿងដែលគាត់ជាភាគី។

៦. អង្គបុរេជំនុំជម្រះយល់ឃើញថា សេចក្តីពិចារណាទាំងឡាយនៅក្នុងសេចក្តីសម្រេចលើសំណើរបស់លោក អៀង សារី អនុវត្តចំពោះករណីនេះ ហើយអង្គបុរេជំនុំជម្រះមិនឃើញមានភស្តុតាងរឹងមាំ ដែលអាចឱ្យខ្លួនធ្វើការសន្និដ្ឋានខុសពីនេះ នៅក្នុងសំណើមួយនេះឡើយ។

៧. នៅក្នុងដំណាក់ការនេះនៃនីតិវិធី អង្គបុរេជំនុំជម្រះយល់ឃើញទៀតថា ខ្លួននឹងទទួលបានការផ្តល់អំណះអំណាងគ្រប់គ្រាន់តាមរយៈនីតិវិធីដែលខ្លួនបានបង្គាប់ ដើម្បីសម្រេចលើបណ្តឹងឧទ្ធរណ៍នេះ។ អង្គបុរេជំនុំជម្រះយល់ឃើញបន្តទៀតថា "ភាពមិនមានតុល្យភាពនៅក្នុងការដាក់ជូនអំណះអំណាង" ដែលត្រូវបានគេមើលឃើញនោះ នឹងមិនប៉ះពាល់ដល់ភាពយុត្តិធម៌នៃការចេញសាលដីការបស់អង្គបុរេជំនុំជម្រះឡើយ។[២]

៨. ដូចដែលអង្គបុរេជំនុំជម្រះ បានសម្រេចនៅក្នុងសេចក្តីសម្រេចនៃសំណើរបស់លោក អៀង សារី អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា វាជាអំណាចរបស់តុលាការដែលថា នៅពេលដែលកិច្ចដំណើរការនីតិវិធីមួយចំនួនកំពុងតែដោះស្រាយ, សេចក្តីសម្រេចនៅក្នុងរឿងក្តីមួយលើបញ្ហាអង្គច្បាប់នឹងផ្តល់ជាបទដ្ឋានណែនាំដល់តុលាការនៅក្នុងរឿងក្តីស្រដៀងគ្នានាពេលអនាគត ក្នុងករណីដែលមិនមានលេចចេញកាលៈទេសៈ ឬអំណះអំណាងថ្មី។ ចំណុចនេះមិនមែនកើតចេញពីករណីដែលថា ស្ថានភាពដែលជនត្រូវចោទមានសិទ្ធិចូលអន្តរាគមន៍នៅក្នុងសំណុំរឿង ដែលខ្លួនមិនមែនជាភាគី ដើម្បីដាក់ជូនការយល់ឃើញរបស់ខ្លួនលើបញ្ហាណាមួយនោះទេ។

**ហេតុដូច្នេះ អង្គបុរេជំនុំជម្រះ÷**

បដិសេធចោលសំណើនេះ។ [handwritten initials]

ភ្នំពេញ ថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០០៨
**ប្រធានអង្គបុរេជំនុំជម្រះ**

អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. * C.E.T.C.

**ប្រាក់ គឹមសាន**

[២] សំណើ វាក្យខណ្ឌទី ១៥។